ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ: ១០៩៧ មស.ក្រខ

ថ្ងៃ ៣ ១ កើត ខែ ផល្គុន ឆ្នាំច ស័ម្រឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ៣ ឆ្នាំ២០១៩

## សូមគោរពជូន

## សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន

**កម្មវត្ថុ ៖** ស្តីពីការផ្តល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៩។

**យោង ៖**
- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ១១៥៧៧ សហវ.អថ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ៩៦២៦ សហវ.អថ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- របាយការណ៍ស្តីពីផែនការក្របខណ្ឌឆ្នាំ២០១៩ របស់ក្រសួង ស្ថាប័ន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានយល់ព្រមផ្តល់ជាគោលការណ៍ជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិលចំនួន **៥,៩៩៦កន្លែង** មន្ត្រីជាប់កិច្ចសន្យាចំនួន **១៨,២៩២នាក់** និងគ្រូបង្រៀនជាប់កិច្ចសន្យាចំនួន **៧,៩៩៦នាក់** គ្រូបង្រៀនពីថ្នាក់ពីរពេលចំនួន **១២,៨៩៧នាក់** គ្រូបង្រៀនថ្នាក់គួប២ចំនួន **២,៥៩៨នាក់** គ្រូបង្រៀនថ្នាក់គួប៣ចំនួន **១២០នាក់** គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធចំនួន **២,៤៧២នាក់** និងគ្រូបង្រៀនជាប់កិច្ចសន្យាខ្មែរឥស្លាមចំនួន **១៧៨នាក់** ដើម្បីផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ដូចមានខាងក្រោម៖

| ល.រ | ក្រសួង ស្ថាប័ន | ផែនការក្របខណ្ឌឆ្នាំ២០១៩ | | | |
|---|---|---|---|---|---|
| | | ក្របខណ្ឌ | មន្ត្រីជាប់កិច្ចសន្យា | គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា | ឆ្នាំទំនប់ប្រព័ន្ធធារាសាស្ត្រ |
| ១ | ព្រះបរមរាជវាំង | ០៩ | ២៥០ | | |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ២១ | ១១២ | | |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ១៦ | ៥២ | | |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០០ | ១៤៣ | | |
| ៥ | មហាផ្ទៃ (ទីស្តីការក្រសួង) | ២០ | ៧៩ | | |
| ៥.១ | មហាផ្ទៃ (រដ្ឋបាលថ្នាក់ក្រោមជាតិ) | ២៤៩ | ១៣០៥ | | |
| ៦ | ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិង | ០៦ | ២៥០ | | |



ផ្លូវវិថ្ថអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh